Travellers

# ជំងឺប៉េស្តជ្រូកអាហ្វ្រិក



## ការពារប្រទេសអូស្ត្រាលីកុំឲ្យមានឆ្លងជំងឺប៉េស្តជ្រូកអាហ្វ្រិក

ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) គឺជាជំងឺសត្វជ្រូកបង្កដោយវីរុសឆ្លងខ្លាំងបំផុត ហើយរាលដាលយ៉ាងឆាប់រហ័ស និងធ្វើឲ្យមហន្តរាយដល់ឧស្សាហកម្មសាច់ជ្រូក អូស្ត្រាលី ប្រសិនបើជំងឺនេះវាយលុក។

ជំងឺនេះឆ្លងរាលដាលតាមរយៈការប៉ះពាល់ផ្ទាល់ជាមួយសត្វជ្រូកមានជំងឺ រថយន្ត ឬសម្ភារៈដឹកជញ្ជូនសត្វដែលមានជំងឺ ឬដោយសំលៀកបំពាក់ដែលមានមេរោគ និងតាមរយៈការឲ្យចំណីដែលមានលាយឡំជាមួយផលិតផលសត្វ ឬសំណល់សាច់ដែលមានមេរោគ ដល់សត្វជ្រូក។

ដូចនេះការទប់ស្កាត់មិនឲ្យជំងឺនេះ (ASF) ចូលមកប្រទេសអូស្ត្រាលី គឺជារឿងសំខាន់ណាស់ ហើយយើងត្រូវការការរួមចំណែកពីលោកអ្នក ពេលធ្វើដំណើរមកប្រទេសអូស្ត្រាលី ឬធ្វើការនៅក្នុងប្រទេសអូស្ត្រាលី។

### មុនពេលអ្នកធ្វើដំណើរ

- ចូរកុំយកសាច់ ឬផលិតផលធ្វើពីសាច់ពីប្រទេសរបស់អ្នកមកកាន់ប្រទេសអូស្ត្រាលី។
- ចូរកុំយកសំលៀកបំពាក់ ឬសម្ភារៈផ្សេងៗដែលប្រើប្រាស់ពេលមើលថែសត្វជ្រូកនៅប្រទេសរបស់អ្នកមកកាន់ប្រទេសអូស្ត្រាលី។
- ប្រសិនបើអ្នកបានប៉ះពាល់សត្វជ្រូកនៅប្រទេសរបស់អ្នក ចូររង់ចាំប្រាំពីរថ្ងៃមុនពេលប៉ះពាល់ជ្រូក ឬជៀសវាងប៉ះពាល់សត្វជ្រូកនៅអូស្ត្រាលី។

### ពេលមកដល់អូស្ត្រាលី

ប្រទេសអូស្ត្រាលីមានវិធានការចត្តាឡីស័កយ៉ាងតឹងតែងបំផុតលើសាច់ ឬផលិតផលធ្វើពីសត្វពេលចូលមកកាន់ប្រទេសនេះ។

- ចូរធ្វើការប្រកាសពីផលិតផលទាំងអស់ ដោយរួមបញ្ចូលទាំងម្ហូបអាហារ ផលិតផលធ្វើពីសត្វ ឬរុក្ខជាតិ ផ្សេងៗដែលមានបញ្ជាក់នៅក្នុងប័ណ្ណសម្រាប់អ្នកដំណើរចូលមកអូស្ត្រាលី។
- ប្រសិនបើអ្នកមិនធ្វើការប្រកាសពីអ្វីដែលយកចូល មានដូចជាសាច់ ឬផលិតផលធ្វើពីសត្វ អ្នកអាចនឹងរងការផាកពិន័យ។

### ការរក្សាភូមិគាមអនាម័យ និងការរក្សាអនាម័យឲ្យបានល្អ នៅក្នុងអូស្ត្រាលី

ចូរកុំឲ្យម្ហូបចំណីធ្វើពីសាច់សត្វ ឬម្ហូបអាហារទាំងឡាយណាដែលបានប្រឡាក់ប៉ះពាល់ជាមួយផលិតផលធ្វើពីសាច់សត្វដល់សត្វជ្រូក។ ការធ្វើដូចនេះគឺខុសច្បាប់។ នៅពេលចូលកសិដ្ឋាន ឬទីកន្លែងផលិត ចូរប្រើប្រាស់៖

- ឧបករណ៍ដែលមាននៅកន្លែងផលិត ស្បែកជើងកវែង និងសម្ភារៈផ្សេងៗប្រសិនបើផ្តល់ជូន
- ធុងទឹកសម្រាប់លាងស្បែកជើង
- ថ្នាំសម្លាប់មេរោគសមស្របដូចជា ក្លរ ដើម្បីសម្អាតសម្ភារៈ

### ពេលចាកចេញពីកសិដ្ឋាន

- លាងសម្អាតឬបាញ់ថ្នាំសម្លាប់មេរោគលើស្បែកជើង សំលៀកបំពាក់ រថយន្ត និងសម្ភារៈផ្សេងៗដែលអ្នកយកទៅជាមួយ។

**យើងទាំងអស់គ្នាមានការទទួលខុសត្រូវរួមគ្នាក្នុងការការពារប្រទេសអូស្ត្រាលីទប់ទល់នឹងជំងឺ ASF។**

**ប្រសិនបើមានអ្វីគួរឲ្យសង្ស័យ សូមទូរស័ព្ទទៅកាន់លេខ 1800 798 636.**

NORTHERN TERRITORY GOVERNMENT